# ធម៌សុខោ

**សុខោ ពុទ្ធានមុប្បាទោ** កិរិយាកើតឡើងនៃព្រះពុទ្ធទាំងឡាយ ជាទីនាំមកនូវសេចក្តីសុខ។

**សុខា សទ្ធម្មទេសនា** កិរិយាសំដែងនូវព្រះសទ្ធម្មគឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ជាទីនាំមកនូវសេចក្តីសុខ។

**សុខា សង្ឃស្ស សាមគ្គី** សេចក្តីព្រមព្រៀងគ្នានៃសង្ឃ ជាទីនាំមកនូវសេចក្តីសុខ។

**សមគ្គានំ តបោ សុខោ** តបៈគុណនៃព្រះសង្ឃទាំងឡាយ អ្នកព្រមព្រៀងគ្នា ជាទីនាំមកនូវសេចក្តីសុខ។

**ទិវាតបតិ អាទិច្ចោ** ព្រះអាទិត្យរុងរឿងបានតែក្នុងវេលាថ្ងៃ។

**រត្តិមាភាតិ ចន្ទិមា** ព្រះចន្ទរុងរឿងបានតែក្នុងវេលាយប់។

**សន្នទ្ធោ ខត្តិយោ តបតិ** ព្រះមហាក្សត្រលុះតែទ្រង់គ្រឿងប្រដាប់សម្រាប់រាជ្យ ទើបរុងរឿងបាន។

**ឈាយី តបតិ ព្រាហ្មណោ** ព្រាហ្មណ៍លុះតែចំរើននូវឈានទើបរុងរឿងបាន។

**អថ សព្វមហោរត្តឹ ពុទ្ធោ តបតិ តេជសា** ឯព្រះពុទ្ធជាម្ចាស់ ទ្រង់រុងរឿងដោយតេជះទាំងថ្ងៃទាំងយប់។

**ឯតេន សច្ចវជ្ជេន សុវត្ថិ ហោតុ សព្វទា** សេចក្តីសុខសួស្តី សូមកើតមានក្នុងកាលទាំងពួងដោយកិរិយាពោលនូវពាក្យសច្ចៈនេះ។

**ហិរិ ឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា**

**សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេ**

សប្បុរសទាំងឡាយ មានចិត្តរម្ងាប់ប្រកបព្រមហើយ ដោយហិរិ និង ឱត្តប្បៈ (ថែមទាំង) មានចិត្តចុះស៊ប់ចំពោះធម៌មានពណ៌ស (គឺសុចរិតធម៌)។ អ្នកប្រាជ្ញទាំងឡាយលោកឱ្យនាមថា អ្នកមានទេវធម៌ក្នុងលោក



**ចម្លងជូនដោយខ្ញុំបាទ វ៉ាន់ អ៊ុង ឆ្នាំរោងចត្វាស័ក ព.ស.២៥៥៦**

វាយចម្លងដាក់គេហទំព័រវត្តដោយខ្ញុំបាទ **អ៊ិន លី** ថ្ងៃទី២៧ ខែវិច្ឆិកា គ.ស.២០១២

# ធម៌សុខោ-បាលី

សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា
សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ
ទិវាតបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា
សន្នទ្ធោ ខត្តិយោ តបតិ ឈាយី តបតិ ព្រាហ្មណោ
អថ សព្វមហោរត្តឹ ពុទ្ធោ តបតិ តេជសា
ឯតេន សច្ចវជ្ជេន សុវត្ថិ ហោតុ សព្វទា
ហិរិ ឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា
សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេ

វត្តអង្គរាជ

**ចម្លងជូនដោយខ្ញុំបាទ វ៉ាន់ អ៊ុង ឆ្នាំរោងចត្វាស័ក ព.ស.២៥៥៦**

វាយចម្លងដាក់គេហទំព័រវត្តដោយខ្ញុំបាទ **អ៊ិន លី** ថ្ងៃទី២៧ ខែវិច្ឆិកា គ.ស.២០១២

វត្តអង្គរាជ

